ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
លេខៈ ១៩៣០ ដនស/គដនដ.

ថ្ងៃពុធ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ ២០១៨

**ជម្រាបជូន**
**ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងជា**
**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត**

**កម្មវត្ថុ:** អំពីការកំណត់កម្ពស់ជាន់នីមួយៗនៃអគាររោងចក្រវាយនភណ្ឌ
**យោង:** - អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- ប្រកាសលេខ ១២៥ ស.ក.ប.យ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការបញ្ចេញបញ្ចូលខ្យល់ និងការសំអាតបរិយាកាសក្នុងទីកន្លែងធ្វើការ
- ប្រកាសអន្តរក្រសួងលេខ ០០២ ដ.ន.ស/ប្រ.ក ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ ២០១៤ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងត្រួតពិនិត្យ និងបញ្ជាក់សុវត្ថិភាពសំណង់រោងចក្រផ្នែកវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាល** និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ជ្រាបថា ដើម្បីធានាបាននូវផាសុកភាព សុវត្ថិភាពនិងបរិស្ថានការងារល្អ គ្រប់សំណើសុំសាងសង់អគាររោងចក្រវាយនភណ្ឌត្រូវ៖

១. កំណត់កម្ពស់ជាន់នីមួយៗពីផ្ទៃកម្រាលទៅពិដាននៃអគារឱ្យបានយ៉ាងតិច ៩ (ប្រាំបួន) ម៉ែត្រ

២. រៀបចំប្រព័ន្ធខ្យល់ចេញ-ចូលតាមធម្មជាតិ ឬសិប្បនិម្មិត ដូចខាងក្រោម៖
- រៀបចំឱ្យមានប្រព័ន្ធខ្យល់ចេញ-ចូលតាមធម្មជាតិ ដោយមានផ្ទៃក្រឡាទ្វារ បង្អួច ឬរន្ធខ្យល់សរុបយ៉ាងតិចស្មើនឹងមួយភាគបួន (១/៤) នៃផ្ទៃក្រឡាបាតអគារ ឬ
- រៀបចំឱ្យមានប្រព័ន្ធខ្យល់ចេញ-ចូលតាមបែបសិប្បនិម្មិត ដោយឧបករណ៍គ្រឿងយន្តស្រូបខ្យល់ចេញ-ចូល និងត្រូវមានផ្ទៃក្រឡាទ្វារ បង្អួច ឬរន្ធខ្យល់សរុបយ៉ាងតិចស្មើនឹងមួយភាគបួន (១/៤) នៃផ្ទៃក្រឡាបាតអគារ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាល** និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអគ្គលេខាធិការដ្ឋាន ក្រោមក្រសួង ដ.ន.ស.
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com